ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

សន្តានព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៦៨៥
ចុះថ្ងៃទី២០-០៩-២០០៥
សាលដីកាព្រហ្មទណ្ឌ
លេខ: ១២៧"ក្រ.II សវ"
ចុះថ្ងៃទី០៦-១១-២០០៩

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ២០០៩ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- ឯកឧត្តម [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៦៨៥ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០០៥ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទថន ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ មុខរបររត់គុ កើតនៅភូមិកំចាយមា ឃុំស្រញ៉ូង ស្រុកកំចាយមា ខេត្តព្រៃវែង ទីលំនៅសព្វថ្ងៃ [redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន (ដើមបណ្តឹងឧទ្ធរណ៍)។

មានលោក [redacted] យី ជាមេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ច័ន្ទថន។

<u>ជាប់ចោទពីបទ:</u> ប៉ុនប៉ងធ្វើមនុស្សឃាត និងប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៤ និង មាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- ជនរងគ្រោះឈ្មោះ [redacted] កាំយុន ភេទស្រី អាយុ ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរលក់គុយទាវ ទីលំនៅសព្វថ្ងៃ [redacted] ផ្លូវ ១០៥ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ។
- ជនរងគ្រោះឈ្មោះ [redacted] គួយ ភេទប្រុស អាយុ ៦៥ឆ្នាំ ជាតិខ្មែរ មុខរបរលក់គុយទាវ ទីលំនៅសព្វថ្ងៃ [redacted] សង្កាត់អូរឫស្សី ៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

- ជនរងគ្រោះឈ្មោះ [redacted]មិន ហៅ ថៃ ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ មុខរបរសិស្ស ទីលំនៅសព្វថ្ងៃ[redacted] សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:**

តាមពាក្យបណ្តឹង ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០០៤ របស់ជនរងគ្រោះឈ្មោះ [redacted] គួយ បានបញ្ជាក់ថា នៅថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០០៤ វេលាម៉ោង ១ និង៤៥នាទី ពេលនោះជនរងគ្រោះកំពុងដេកលក់ក្នុងបន្ទប់ ស្រាប់តែជនល្មើសឈ្មោះ [redacted] ច័ន្ទថន បានលបចូលក្នុងបន្ទប់ដេក ហើយកាន់កូនកាំបិតចាក់បំពង់កជនរងគ្រោះ បណ្តាលឲ្យបាក់ដងកាំបិត បន្ទាប់មកជនល្មើសយកកាំបិតតាំងគោកាប់មកលើជនរងគ្រោះ ហើយត្រូវបានជនរងគ្រោះស្រែកឲ្យប្រពន្ធកូនមកជួយ តែត្រូវជនល្មើសកាប់បណ្តាលឲ្យរងរបួសប្រពន្ធកូនថែមទៀត។ ក្រោយមកផ្អើលដល់អ្នកជិតខាង និងសមត្ថកិច្ច ហើយសមត្ថកិច្ចចាប់ជនល្មើសបញ្ជូនទៅអធិការនគរបាលខណ្ឌ៧មករា តែម្តង។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៦៦ ច ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាដំបូងក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោសលើឈ្មោះ[redacted] ច័ន្ទថន ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០០៤ ពីបទ ប្លន់ និងប៉ុនប៉ងធ្វើមនុស្សឃាត តាមមាត្រា ៤ និងមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០០៤។

២- ទុកសិទ្ធិឲ្យជនរងគ្រោះប្តឹងទាមទារសំណងផ្សេងៗ នៅពេលក្រោយបាន។

៣- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនល្មើស កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។ សម្រេចបើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០០៥ របស់ឈ្មោះ [redacted] ច័ន្ទថន ជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦៦ ច ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាដំបូងក្រុងភ្នំពេញ គ្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។
- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។
- បានឃើញរបាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

- ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទថន (អវត្តមាន)
- ជនរងគ្រោះឈ្មោះ [redacted] កាំយុន, [redacted] គួយ, [redacted] មិន (អវត្តមាន)

- លោក [redacted] យី ជាមេធាវីការពារជនជាប់ចោទ (វត្តមាន)

តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ធ្វើសេចក្តីសន្និដ្ឋានថា: ជនជាប់ចោទបានឆ្លើយសារភាព មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទដូចការចោទប្រកាន់របស់តំណាងមហាអយ្យការ។ សំអាងហេតុ និងសេចក្តីសម្រេចរបស់សាលាដំបូងដែលបានសម្រេចមកមានលក្ខណៈត្រឹមត្រូវ គប្បីតម្កល់ទុកជាបានការ។

លោក [redacted] យី ជាមេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ច័ន្ទថន ធ្វើសេចក្តីសន្និដ្ឋានថា: នៅថ្ងៃកើតហេតុកូនក្តីខ្លួនបានចូលលួចទ្រព្យសម្បត្តិ ពេលចូលទៅលួចដោយម្ចាស់ផ្ទះទាន់ក៏ប្រតាយប្រតប់គ្នា ហើយសាលាដំបូងបានដាក់ទណ្ឌកម្មកូនក្តីខ្លួនខ្ពស់ពេករហូតដល់ ១៥ឆ្នាំ។ សំណូមពរ សុំប្តូរបទចោទប្រកាន់ពីប៉ុនប៉ងមនុស្សឃាត មកបទ បង្ករបួសស្នាមវិញ។

- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិនិត្យពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សភាព្រហ្មទណ្ឌ យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០០៥ របស់ឈ្មោះ [redacted] ច័ន្ទថន ជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦៦ ច ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច បានធ្វើឡើងត្រឹមត្រូវក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌទទួលជំនុំជម្រះបាន។

២-តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោលឃើញថាកាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៤ វេលាម៉ោង ១ និង៤៥នាទីយប់ ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទថន បានលបចូលទៅក្នុងបន្ទប់ដេករបស់ជនរងគ្រោះឈ្មោះ [redacted] គួយ ហើយយកកាំបិតចុងស្រួចចាក់ជនរងគ្រោះមួយកាំបិតចំបំពង់ក ហើយបានយកកាំបិតតាំងគោកាប់ជនរងគ្រោះបន្ថែមទៀត តែដោយជនរងគ្រោះស្រែកទើបប្រពន្ធកូនជនរងគ្រោះភ្ញាក់ ក៏ត្រូវជនជាប់ចោទកាប់រងរបួសដៃ។ បន្ទាប់មកក៏មានការផ្អើលដល់អ្នកជិតខាង ហើយសមត្ថកិច្ចក៏ដល់ចាប់ខ្លួនជនជាប់ចោទយ៉ាងជាក់ស្តែងតែម្តង ដែលជាអំពើមានធាតុផ្សំ និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ ពីបទ ប្លន់ និងប៉ុនប៉ងមនុស្សឃាតដោយចេតនា តាមមាត្រា ០៤ និងមាត្រា ០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដូចមានក្នុងផ្នែកសំអាងហេតុនៃសេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញបញ្ជាក់ស្រាប់ ហើយដែលសភាព្រហ្មទណ្ឌឯកភាពលើសំអាងហេតុទាំងនេះ។ ហេតុដូច្នេះ សភាព្រហ្មទណ្ឌមិនចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតទេ។

ម្យ៉ាងទៀត តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ បានប្តឹងសុំសភាព្រហ្មទណ្ឌតម្កល់សេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ដែលចំណុចនេះគប្បីសភាព្រហ្មទណ្ឌពិចារណាតាមច្បាប់។

៤- សាលក្រមព្រហ្មទណ្ឌលេខ ៦៦ ច ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ដែលគប្បីសភាព្រហ្មទណ្ឌសម្រេចតម្កល់ទុកជាបានការតាមច្បាប់តទៅ។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០០៥ របស់ឈ្មោះ [redacted] ច័ន្ទថន ជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៦ ច ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ។

៣- បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ច័ន្ទថន តាមនីតិវិធីច្បាប់។

៤- សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០០៥ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

បើកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំង គ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

**ក្រឡាបញ្ជី**
ហត្ថលេខា: [redacted]

**ចៅក្រមប្រឹក្សា**
ហត្ថលេខា [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា [redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី 16 ខែ 6 ឆ្នាំ ២០១៤
**ក្រឡាបញ្ជី**
[redacted]

បានឃើញ
**ប្រធានសាលាឧទ្ធរណ៍**
[redacted]